00641031

E15/2

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 31 / 01 / 2011
ម៉ោង (Time/Heure): 14 : 45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**សារណាតបរបស់ អៀង សារី ទៅនឹងចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើជាបន្ទាន់របស់ អៀង សារី សុំកុំឲ្យចាប់ផ្តើមចិរវេលាសម្រាប់អញ្ញត្រកម្មរហូតដល់ពេលអង្គបុរេជំនុំជម្រះ បាន ផ្តល់សំអាងហេតុទៅលើសាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ**

&

**សំណើជាបន្ទាន់សុំពេលវេលាបន្ថែម និងបង្កើនចំនួនទំព័រកំណត់ ដើម្បីដាក់បណ្តឹងអំពីអញ្ញត្រកម្ម តាមវិធាន ៨៩**

---

ផ្ញើជូន៖
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន
ចៅក្រម ធូ មណី
ចៅក្រម យ៉ា សុខន

ដាក់ដោយ៖
សហមេធាវីរបស់លោក អៀង សារី
លោក អាង ឧត្តម
លោក Michael G. KARNAVAS

E15/2

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសជ

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង យូរ ឧត្តរា

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**



សារណាតបរបស់ អៀង សារី ទៅនឹងចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើជាបន្ទាន់របស់ អៀង សារី សុំកុំឱ្យចាប់ផ្តើម ចិរវេលាសម្រាប់អញ្ញត្រកម្មរហូតដល់ពេលអង្គបុរេជំនុំជម្រះ បាន ផ្តល់សំអាងហេតុទៅលើសាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ & សំណើជាបន្ទាន់សុំពេលវេលាបន្ថែម និងបង្កើនចំនួន ទំព័រកំណត់ ដើម្បីដាក់បណ្តឹងអំពីអញ្ញត្រកម្ម តាមវិធាន ៨៩

Original EN: 00640404-00640409

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") សូមឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើជាបន្ទាន់របស់ អៀង សារី សុំកុំឱ្យចាប់ផ្តើមថិរវេលា និងសំណើជាបន្ទាន់សុំពេលវេលាបន្ថែម និងបង្កើនចំនួនទំព័រកំណត់ ទាក់ទិននឹងអញ្ញត្រកម្មតាមវិធាន ៨៩ ("ចម្លើយតប")[1]។ ការអះអាងជាសំខាន់នៅក្នុងចម្លើយតបគឺថា ថិរវេលាក្នុងការដាក់អញ្ញត្រកម្មគួរតែចាប់ផ្តើមគិតចាប់ពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ហើយថា ការសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រពុំគួរអនុញ្ញាតឡើយ។ ចម្លើយតបមានលក្ខណៈមិនពេញលេញ ទាំងនៅក្នុងខ្លឹមសារ និងសំអាងហេតុ។ អង្គជំនុំជម្រះសាលាដំបូងត្រូវតែបដិសេធចម្លើយតបនេះ។

I. **សារណាតប**

១. ក្នុងកថាខណ្ឌ ២ ក.ស.ព អះអាងថា ដីកាដំណោះស្រាយបានចូលជាស្ថាពរតាំងពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០០១ ហើយថា ថិរវេលា ៣០ថ្ងៃ សម្រាប់លើកឡើងនូវអញ្ញត្រកម្ម បានចាប់ផ្តើមគិតចាប់ពីកាលបរិច្ឆេទនេះ។ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ គឺជាថ្ងៃដែលក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងជាផ្លូវការពីអង្គបុរេជំនុំជម្រះ[2]។ អង្គជំនុំជម្រះសាលាដំបូងបានប្រើថ្ងៃទី១៤ ខែមករា ជាថ្ងៃចាប់ផ្តើមថិរវេលា ដែលតម្រូវឱ្យភាគីទាំងអស់ផ្តល់នូវសម្ភារៈនៃអង្គហេតុមួយចំនួន[3]។ មិនដូចជាបញ្ហាផ្នែកយុត្តាធិការទេ <u>បញ្ហាអង្គហេតុ</u>ពុំពឹងផ្អែកទៅលើសំអាងហេតុ របស់អង្គបុរេជំនុំជម្រះទេ ដែល ក.ស.ព ហាក់ដូចជាទទួលស្គាល់[4]។ វាមិនទំនង

---

[1] សំណុំរឿង អៀង សារី, ០០២/១៩-០៩-២០០៧/អវសជ, ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើជាបន្ទាន់របស់ អៀង សារី សុំកុំឱ្យចាប់ផ្តើមថិរវេលា និងសំណើជាបន្ទាន់សុំពេលវេលាបន្ថែម និងបង្កើនចំនួនទំព័រកំណត់ ទាក់ទិននឹងអញ្ញត្រកម្មតាមវិធាន៨៩, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១, ឯកសារ E15/1, ERN: 00640111-00640115។

[2] សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧/អវសជ, ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១, ឯកសារ E9, ERN: 00635754-00635759, កថាខណ្ឌ២។

[3] *ដូចដើងទំព័រខាងលើ។*

[4] *សូមមើល រឿងក្តី នួន ជា,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវសជ, សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាលើសំណើបន្ទាន់របស់មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ និង នួន ជា សុំឱ្យបញ្ជាក់ថ្ងៃផុតកំណត់, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១, ឯកសារ

ឡើយក្នុងការស្នើឡើងថា មេធាវីការពារក្តីគួរតែដាក់អញ្ញត្រកម្មទាក់ទិននឹងយុត្តាធិការនៃអង្គជំនុំជម្រះសាលាដំបូង ដោយពុំបានដឹងអំពីសំអាងហេតុច្បាស់លាស់របស់អង្គបុរេជំនុំជម្រះស្តីពីបញ្ហាទាំងនោះសោះ។ បើដូច្នេះមែន ចម្លើយតបរបស់ ក.ស.ព គឺដូចគ្នាទៅនឹងការលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ដោយពុំទទួលផលប្រយោជន៍ពីសំអាងហេតុរបស់អង្គបុរេជំនុំជម្រះឡើយ។ ជំហរដែលគួរអោយអស់សំណើចនិងគ្មានភាពសមហេតុផល ត្រូវតែបដិសេធចោល។

២. អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចផ្តល់សំអាងហេតុចំពោះសាលដីការបស់ខ្លួន[5]។ អង្គបុរេជំនុំជម្រះពុំទាន់បានផ្តល់សំអាងហេតុចំពោះសាលដីការបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយនៅឡើយទេ[6]។ រហូតមកដល់ពេលនេះ អង្គបុរេជំនុំជម្រះបានចេញសាលដីកាមួយ ដែលសំអាងហេតុនៃដីកានេះ "នឹងធ្វើឡើងនៅពេលវេលាសមស្រប" [7]។ ករណីនេះអាចដោយសារតែជនជាប់ចោទនឹងត្រូវដោះលែងពីមន្ទីរឃុំឃាំង ប្រសិនបើសាលដីកាមិនត្រូវបានចេញនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១១ ក្នុងរយៈពេល ៤ខែ បន្ទាប់ពីការចេញដីកាដំណោះស្រាយ[8]។ មេធាវីការពារក្តីទទួលស្គាល់ទំហំការងាររបស់អង្គបុរេជំនុំជម្រះ ដែលវាត្រូវការពេលវេលាច្រើនដើម្បីធ្វើការវិភាគ និងផ្តល់សាលដីកាដោយមានសំអាងហេតុទាក់ទិននឹងការជំទាស់ផ្នែកយុត្តាធិការដែលមានលក្ខណៈស្មុគស្មាញ និងដើម្បីបកប្រែសាលដីកានេះជាច្រើនភាសានោះ។

---

E14/1, ERN: 00640189-00640193, កថាខណ្ឌ ៣។ "មេធាវីការពារក្តីពុំបានពន្យល់ថាតើ លទ្ធភាពរបស់ខ្លួនក្នុង ការចងក្រងបញ្ជីសាក្សី នឹងត្រូវប៉ះពាល់យ៉ាងដូចម្តេចឡើង នៅពេលខ្លួនពុំអាចពិនិត្យមើលសំអាងហេតុជាក់លាក់ដែលជាមូលដ្ឋាននៃការសម្រេចរបស់អង្គបុរេជំនុំជម្រះលើមូលដ្ឋាន *តាមយុត្តាធិការ* នៃបណ្តឹងឧទ្ធរណ៍..."

[5] វិធាន ៧៧(១៤)។

[6] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អជប ៧៥), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១, ឯកសារ D427/1/26, ERN: 00634887-00634891, ទំព័រ៤។

[7] *ដូចដើងទំព័រខាងលើ។*

[8] យោងវិធាន៦៨(៣)។

ទាំងនេះគឺជាការលំបាកដូចគ្នាដែលមេធាវីការពារក្តីនឹងជួបប្រទះ នៅពេលដែលខ្លួនត្រូវបង្ហាញអញ្ញត្រកម្មរបស់ខ្លួនទៅអង្គជំនុំជម្រះសាលាដំបូង។ ដូច្នេះ មេធាវីការពារក្តីស្នើសុំឱ្យបន្ថែមពេលវេលាថែមទៀត។ មេធាវីការពារក្តីប្រាកដជាមិនត្រូវរងផលប៉ះពាល់ ដោយសារតែការពន្យារពេលរបស់អង្គបុរេជំនុំជម្រះក្នុងការចេញសាលដីកាដែលមានសំអាងហេតុពេញលេញ ហើយមេធាវីការពារក្តីក៏ពុំគួរត្រូវបានបង្ខំឱ្យដាក់អញ្ញត្រកម្ម ដែលផ្អែកទៅលើសំអាងហេតុស្មានៗមិនច្បាស់លាស់ឡើយ។

៣. ក្នុងកថាខណ្ឌ ៣ ក.ស.ព អះអាងថា មេធាវីការពារក្តី មិនគួរត្រូវបានអនុញ្ញាតឱ្យអនុវត្តផ្ទុយពីវិធានឡើយ ពីព្រោះវិធាន ៨៩ ឆ្លុះបញ្ចាំងជាពិសេសអំពីសេចក្តីសន្និដ្ឋានរបស់អ្នកតាក់តែងវិធានដែលកំណត់ថា រយៈពេលសាមសិបថ្ងៃ គឺជាពេលវេលាគ្រប់គ្រាន់សម្រាប់ត្រៀមរៀបចំអញ្ញត្រកម្មតវ៉ាអំពីបញ្ហាយុត្តាធិការរបស់តុលាការ ឬបញ្ហាណាមួយដែលតម្រូវឱ្យមានការរំលត់បណ្តឹងអាជ្ញា"។ វិធានពុំបានចែងអំពីស្ថានភាពមួយដែលកើតមាន នៅពេលដែលសេចក្តីសម្រេចត្រូវបានចេញ "ដោយមានសំអាងហេតុនៅពេលក្រោយ" ឡើយ។ អ្នកតាក់តែងវិធាន ពុំបានគិតទៅដល់សេណារីយ៉ូបែបនេះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ វិធាន៣៩(៤)(ក) ចែងថា ៖ "តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាច ក.) ពន្យារពេលវេលាកំណត់ ដែលខ្លួនបានសម្រេច"។ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិគ្រប់គ្រាន់ក្នុងការអនុញ្ញាតឱ្យដាក់សំណើសុំ ដើម្បីធានាឱ្យមានយុត្តិធម៌។

៤. ក្នុងកថាខណ្ឌ ៣ ក.ស.ព អះអាងបន្ថែមទៀតថា មេធាវីការពារក្តីបានដាក់សំណើទាក់ទិននឹងបញ្ហាផ្នែកយុត្តាធិការមួយចំនួនកាលពីពេលមុនៗទៅ ក.ស.ច.ស និងអង្គបុរេជំនុំជម្រះ ដូច្នេះហើយមេធាវីការពារក្តីបានត្រៀមរៀបចំជាស្រេច ហើយមិនត្រូវការពេលវេលាបន្ថែមក្នុងការដាក់អញ្ញត្រកម្មឡើយ។ នេះគឺជាទឡ្ហីករណ៍មួយមិនសមហេតុផល។ មេធាវីការពារក្តីត្រូវតែធ្វើការវិភាគដោយប្រុងប្រយ័ត្នលើសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ។ ប្រសិនបើពុំមានសំអាងហេតុនោះទេ មេធាវីការពារក្តីមិនអាចរៀបចំការពារលោក អៀង សារី ឱ្យបានត្រឹមត្រូវ និងមានពេលវេលាគ្រប់គ្រាន់ អនុលោមតាមសិទ្ធិក្នុងការទទួលបានការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ឡើយ។ ប្រសិនបើមេធាវីការពារក្តីយល់ឃើញថា សំអាងហេតុរបស់អង្គបុរេជំនុំជម្រះ

ត្រឹមត្រូវ មេធាវីការពារក្តីអាចសម្រេចមិនដាក់អញ្ញត្រកម្មមួយចំនួន។ ក្នុងការបំពេញតួនាទីដោយមានការយកចិត្តទុកដាក់ហ្មត់ចត់[9] និងពុំមានទទួលរងនូវផលប៉ះពាល់ មេធាវីការពារក្តីមិនអាចដាក់តែសំណើដដែលទៅអង្គជំនុំជម្រះសាលាដំបូង ដែលមេធាវីការពារក្តីបានដាក់រួច ហើយទៅ ក.ស.ច.ស ឬអង្គបុរេជំនុំជម្រះនោះឡើយ។

៥. ក្នុងកថាខណ្ឌ ៤ ក.ស.ព អះអាងថា អង្គជំនុំជម្រះសាលាដំបូង មិនជាប់កាតព្វកិច្ចត្រូវតែអនុវត្តតាមអង្គបុរេជំនុំជម្រះនោះទេ ហើយថា "គ្មានហេតុផល ថាតើហេតុអ្វីបានជាអញ្ញត្រកម្មរបស់ជនជាប់ចោទ ដែលនឹងត្រូវធ្វើឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះ នឹងត្រូវទទួលរងផលប៉ះពាល់ដោយសារសាលដីកាសម្រេចពេញលេញរបស់អង្គបុរេជំនុំជម្រះ"។ ទទ្បឹករណ៍នេះមិនបានគិតថា នីតិវិធីរបស់ អ.វ.ត.ក អនុញ្ញាតឱ្យមានបណ្តឹងឧទ្ធរណ៍មុនអង្គសេចក្តី ប្រឆាំងទៅនឹងដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក[10] ហើយបន្ទាប់មកគឺអាចលើកបញ្ហាអញ្ញត្រកម្មទាក់ទិននឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងយ៉ាងយូរ ៣០ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ ប្រសិនបើរឿងក្តីនេះត្រូវបន្តទៅធ្វើសវនាការ[11]។ នីតិវិធីនេះប្រមើលមើលយ៉ាងច្បាស់ថា ភាគីទាំងឡាយនឹងមានផលប្រយោជន៍ពីសំអាងហេតុរបស់អង្គបុរេជំនុំជម្រះចំពោះការកំណត់យុត្តាធិការរបស់ អ.វ.ត.ក នៅ

---

[9] សហមេធាវីការពារក្តីមានកាតព្វកិច្ចក្នុងការយកចិត្តទុកដាក់ហ្មត់ចត់ក្នុងការតំណាងឱ្យលោក អៀង សារី ។ កាតព្វកិច្ចនេះតម្រូវឱ្យមេធាវីការពារក្តីបំពេញការងារដោយយកចិត្តទុកដាក់ដើម្បីការពារផលប្រយោជន៍ និងសិទ្ធិរបស់ លោក អៀង សារី ដូច្នេះហើយមេធាវីការពារក្តីបំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីធានាថា ការជំនុំជម្រះក្តីគាត់មានយុត្តិធម៌។ ការពិភាក្សាអំពីលក្ខខណ្ឌតម្រូវនៃការយកចិត្តទុកដាក់ហ្មត់ចត់ ទាក់ទិននឹងសិទ្ធិក្នុងការទទួលបាននូវពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ម្នាក់កត់សម្គាល់ថា "ពាក់ព័ន្ធនឹងពេលវេលា និងសម្ភារៈរូបវ័ន្ត គឺត្រូវមាន និងពិតណាស់តម្រូវឱ្យមានការយកចិត្តទុកដាក់ដោយមេធាវីការពារក្តី។ <u>មេធាវីការពារក្តីអាចប្តឹងអំពីការរំលោភសិទ្ធិរបស់ពួកគេបាន ប្រសិនបើមេធាវីការពារក្តីបានធ្វើគ្រប់យ៉ាងដែលតម្រូវ</u>ដោយច្បាប់ក្នុងស្រុក ដើម្បីទទួលបាននូវ (ការបន្ថែម) ពេលវេលា ឬសម្ភារៈរូបវ័ន្ត"។ STEPHAN TRECHSEL, HUMAN RIGHTS IN CRIMINAL PROCEEDINGS 214 (Oxford University Press, 2005) (សេចក្តីបញ្ជាក់បន្ថែម)

[10] វិធាន ៧៤(៣)(ក)។

[11] វិធាន ៨៩(១)។

ពេលដាក់អញ្ញត្រកម្មណាមួយ។ នីតិវិធីក៏បានប្រមើលមើលផងដែរថា អង្គជំនុំជម្រះសាលាដំបូងនឹងមានផលប្រយោជន៍ពីសំអាងហេតុនោះ និងការវិភាគរបស់ភាគី នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាលើអញ្ញត្រកម្មណាមួយ។ ជាការពិត អញ្ញត្រកម្មរបស់ជនជាប់ចោទនឹងត្រូវទទួលរងផលប៉ះពាល់ពីសាលដីកាពេញលេញរបស់អង្គបុរេជំនុំជម្រះ។

៦. ក្នុងកថាខណ្ឌ ៤ ក.ស.ព អះអាងទៀតថា សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ រួមបញ្ចូលទាំងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយគ្មានការអូសបន្លាយពេលវេលាដោយមិនសមស្រប។ នេះគឺជាសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលជនជាប់ចោទមាន[12]។ ក.ស.ព មិនអាចប្រើប្រាស់សិទ្ធិនេះដោយព្យាយាមរំលោភទៅលើសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបាននូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួនឡើយ[13]។ គ្រប់ករណីទាំងអស់ ការពន្យារ និងការបន្ថែមពេលវេលាក្នុងការដាក់អញ្ញត្រកម្ម មិនមែនជា "ការអូសបន្លាយពេលវេលាដោយមិនសមស្រប" ឡើយ ជាពិសេសដោយពិចារណាលើមូលហេតុនៃការពន្យារពេលនោះ គឺដោយសារការយឺតយ៉ាវរបស់អង្គបុរេជំនុំជម្រះផ្ទាល់ក្នុងការចេញសាលដីកាដែលមានសំអាងហេតុរបស់ខ្លួន។

៧. ក្នុងកថាខណ្ឌ ៥ ក.ស.ព អះអាងថា ទោះបីជាវាមិនចាំបាច់ឱ្យមេធាវីការពារក្តីលើកឡើងអំពីសំអាងហេតុរបស់អង្គបុរេជំនុំជម្រះនៅក្នុងសារណារបស់ខ្លួន ស្តីពីអញ្ញត្រកម្មក៏ដោយ ក៏សហព្រះរាជអាជ្ញានឹងមិនជំទាស់ទៅនឹងការដាក់សារណាបន្ថែមមួយទៀតឡើយ។ សំណើនេះមិនអាចធ្វើទៅរួចឡើយ។ មេធាវីការពារក្តីនឹងតម្រូវឱ្យរៀបចំសារណាបន្ថែមមួយសម្រាប់អញ្ញត្រកម្មនីមួយៗដែលខ្លួនបានដាក់ បន្ទាប់ពីពេលដែលខ្លួនបានទទួលសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ។

---

[12] *សូមមើល* ICCPR, មាត្រា ១៤(៣)(គ) ដែលផ្តល់ឱ្យជនជាប់ចោទនូវសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយគ្មានការអូសបន្លាយពេលវេលា ដោយមិនសមស្រប។

[13] "ពិចារណាអំពីសេដ្ឋកិច្ច មិនគួររំលោភលើសិទ្ធិរបស់ភាគីក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌" រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Prlić*, IT-04-74-T សេចក្តីសម្រេចលើការអនុម័តវិធានការថ្មីដើម្បីបញ្ចប់ការជំនុំជម្រះក្តីនៅក្នុងពេលមួយដ៏សមស្រប ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ១៦។

បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូង ប្រហែលជាត្រូវពិចារណាពីរដង ព្រោះថានឹងមានសារណាជាច្រើន ប្រសិនបើសំណើរបស់មេធាវីការពារក្ដីបានទទួលការយល់ព្រមតាម។ ដូច្នេះ ចម្លើយតបនាំឱ្យមានការរំលោភដំណើរការរបស់អង្គជំនុំជម្រះសាលាដំបូង។ ការពន្យារពេលវេលាដ៏សាមញ្ញមួយនឹងមានលក្ខណៈត្រឹមត្រូវសមហេតុផលជាងនេះ។

៨. ក្នុងកថាខណ្ឌ ៦ ក.ស.ព អះអាងម្ដងទៀតថា ពេលវេលា ៣០ថ្ងៃ គឺសមស្រប ជាពិសេស ដោយពិចារណាទៅលើការដាក់ឯកសាររបស់មេធាវីការពារក្ដីជាច្រើនលើកពីមុនៗមក ស្ដីពីបញ្ហាទាក់ទិននឹងយុត្តាធិការ។ ក.ស.ព អះអាងថា ប្រសិនបើការបន្ថែមពេលវេលា ត្រូវបានអនុញ្ញាតនោះ អង្គជំនុំជម្រះសាលាដំបូងនឹងមានពេលវេលាតិចជាង សម្រាប់ធ្វើការពិចារណាទៅលើអង្គសេចក្ដីនៃសារណាទាំងនោះ។ ក.ស.ព ពុំបានផ្ដល់នូវឯកសារសំអាងផ្លូវច្បាប់ចំពោះការអះអាងនេះឡើយ ពីព្រោះពុំមានឡើយ។ អង្គជំនុំជម្រះសាលាដំបូង ពុំមានកាលបរិច្ឆេទ ដែលខ្លួនត្រូវសម្រេចទៅលើអញ្ញត្រកម្មឡើយ។ វាជាកំហុសឆ្គងខ្លាំងក្នុងការស្នើឡើងថា អង្គជំនុំជម្រះសាលាដំបូងនឹងផ្ដោតទៅលើការធ្វើសេចក្ដីសម្រេចយ៉ាងឆាប់រហ័ស ដើម្បីចាប់ផ្ដើមសវនាការ ជាជាងការធ្វើសេចក្ដីសម្រេចដោយមានការពិចារណាពេញលេញ ដែលពិចារណាលើគ្រប់ភាពស្មុគស្មាញទាំងអស់ដែលកើតមានឡើងនៅក្នុងបញ្ហាផ្នែកយុត្តាធិការ។

៩. ក្នុងកថាខណ្ឌ ៧ ក.ស.ព អះអាងថា មេធាវីការពារក្ដីមិនគួរត្រូវបានអនុញ្ញាតឱ្យបន្ថែមចំនួន កំណត់ ១៥ទំព័រ សម្រាប់អញ្ញត្រកម្មឡើយ ពីព្រោះកាលៈទេសៈពិសេសដែលសមនឹងទទួលបានការបន្ថែមចំនួនទំព័រ មិនមានអត្ថិភាពឡើយ។ សាលដីកាដែលមានទំហំធំធេងបែបនេះ ដែលត្រូវបានចេញដោយមានសំអាងហេតុនៅពេលក្រោយ បង្កើតបានជាកាលៈទេសៈពិសេសរួចទៅហើយ។ លើសពីនេះទៀត ក.ស.ព អះអាងថា វិធានពុំបានពិចារណាជាក់លាក់ចំពោះការបន្ថែមចំនួនទំព័រសម្រាប់អញ្ញត្រកម្មឡើយ។ វិធានពុំបានកំណត់ចំនួនទំព័រក្នុងការដាក់ឯកសារណាមួយឡើយ។ មានតែសេចក្ដីណែនាំអនុវត្តប៉ុណ្ណោះដែលបានកំណត់បែបនេះនោះ។

១០. ក្នុងកថាខណ្ឌ ៨ ក.ស.ព អះអាងថា ទោះបីជាអង្គជំនុំជម្រះសាលាដំបូងត្រូវអនុញ្ញាតឱ្យមានការបន្ថែមចំនួនទំព័រកំណត់យ៉ាងណាក៏ដោយ ក៏ចំនួន ៤៥ទំព័រដែលមេធាវីការពារក្ដីបានស្នើសុំ នោះ

គឺលើសលប់ពេកហើយ។ ក.ស.ព កត់សម្គាល់ថា អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យមានការបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ ប៉ុន្តែអះអាងថា មេធាវីការពារក្តីអាចលើកនូវមូលដ្ឋាននីមួយៗ ក្នុងចំណោមមូលដ្ឋានទាំងដប់មួយនៃបណ្តឹងឧទ្ធរណ៍របស់ខ្លួនបានក្នុងចំនួន ១៦.៣ ទំព័រសម្រាប់មូលដ្ឋាននីមួយៗនៃបណ្តឹងឧទ្ធរណ៍។ នេះពុំមែនជាវិធីដ៏ត្រឹមត្រូវក្នុងការគណនាចំនួនទំព័រដែលត្រូវលើកនូវបញ្ហាផ្នែកយុត្តាធិការមួយឡើយ។ បញ្ហាខ្លះពិតជាតម្រូវឱ្យមានច្រើនទំព័រ (ព្រមទាំងពេលវេលាច្រើន) ជាងបញ្ហាដទៃទៀត។ ឧទាហរណ៍ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យមេធាវីការពារក្តីពន្យារពេល និងបន្ថែមចំនួនទំព័រ រហូតដល់ ៤០ទំព័រ ដើម្បីពិភាក្សាអំពីភាពអាចអនុវត្តបាននៃ JCE នៅ អ.វ.ត.ក[14]។ ស្រដៀងគ្នានេះដែរ ក.ស.ព ត្រូវបានអនុញ្ញាតឱ្យពន្យារពេល និងបន្ថែមចំនួនទំព័រ ដើម្បីពិភាក្សាអំពីបញ្ហានេះ[15]។

## II. សំណូមពរ

**អាស្រ័យហេតុនេះ** ដោយយោងទៅលើហេតុផលដែលបានបញ្ជាក់ខាងលើ និងផ្អែកទៅលើសំអាងហេតុដែលបានគូសបញ្ជាក់នៅក្នុងសំណើជាបន្ទាន់របស់ អៀង សារី សុំកុំឱ្យចាប់ផ្តើមថិរវេលាសម្រាប់

[14] សំណុំរឿង អៀង សារី ០០២/១៩-០៩-២០០៧-អវតក-កសចស(អជប ៣៥), សេចក្តីសម្រេចស្តីពីសំណើរបស់សហមេធាវីសុំឱ្យពន្យាពេលនៃការដាក់បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជាសហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ D97/14/2, ERN: 00417965-00417967។ សំណុំរឿង អៀង សារី ០០២/១៩-០៩-២០០៧-អវតក-កសចស(អជប ៣៥), សេចក្តីសម្រេចលើសំណើបន្ទាន់របស់ជនត្រូវចោទ អៀង សារី សុំបន្ថែមចំនួនទំព័រដែលបានកំណត់សម្រាប់ពាក្យបណ្តឹងរបស់ជនត្រូវចោទ អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលបានស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី២០ ខែមករា ឆ្នាំ២០១០, ឯកសារ D97/14/4, ERN: 00432771-00432774។

[15] សំណុំរឿង អៀង សារី, ០០២/១៩-០៩-២០០៧-អវតក/កសចស(អជប ៣៥), សេចក្តីសម្រេចលើសំណើសុំពន្យាពេល និងបន្ថែមចំនួនទំព័រ របស់សហព្រះរាជអាជ្ញាក្នុងការដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ, ខៀវ សំផន, អៀង សារី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនប្រឆាំងនឹងដីកាសម្រេចស្តីពីសហកម្មឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០, ឯកសារ D97/16/4, ERN: 00450058-00450061។

E15/2

អញ្ញត្រកម្ម រហូតដល់ពេលអង្គបុរេជំនុំជម្រះបានផ្តល់សំអាងហេតុទៅលើសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើជាបន្ទាន់សុំពេលវេលាបន្ថែម និងបង្កើនចំនួនទំព័រកំណត់ ដើម្បីដាក់បណ្តឹងអំពីអញ្ញត្រកម្ម តាមវិធាន ៨៩ អង្គជំនុំជម្រះសាលាដំបូងគួរតែយល់ព្រមតាមសំណូមពរដែលបានស្នើសុំដោយមេធាវីការពារក្តី អៀង សារី។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១១

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**